ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ ធ៧-០២១-២៣០១៣០-ស.ជ.ណ.

ថ្ងៃអង្គារ ៩រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១

# សារាចរណែនាំ
## ស្តីពី
## ការអនុវត្តចំពោះមូលបត្ររដ្ឋដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

យោងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ប្រកាសលេខធ៧-០០-៤៦ ប្រ.ក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពី អនុបាតសាធនភាពរបស់ធនាគារ ប្រកាសលេខធ៧-០៧-១៣៣ ប្រ.ក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ ស្តីពី អនុបាតសាធនភាពរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងប្រកាសលេខ ធ៧-០១៥-៣៤៩ ប្រ.ក ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៥ ស្តីពី អនុបាតក្របខ័ណ្ឌសន្ទនីយភាព។

ក្នុងគោលបំណងរួមចំណែកក្នុងការអភិវឌ្ឍមូលបត្ររដ្ឋ សំដៅអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ ជំរុញការធ្វើពិពិធកម្មការកៀរគរប្រភពទុនក្នុងស្រុក និងពង្រឹងការអនុវត្តគោលនយោបាយរូបិយវត្ថុ ធនាគារជាតិនៃកម្ពុជា សូមណែនាំការអនុវត្តចំពោះមូលបត្ររដ្ឋដែលកាន់កាប់ដោយគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដូចខាងក្រោម៖

១- ទទួលស្គាល់ការថ្លឹងហានិភ័យ 0% (សូន្យភាគរយ) ចំពោះមូលបត្ររដ្ឋដែលចារឹកជារូបិយវត្ថុជាតិ ឬជារូបិយបណ្ណ ក្នុងការគណនាអនុបាតសាធនភាព និង

២- ទទួលស្គាល់ជាទ្រព្យសកម្មសន្ទនីយដែលមានគុណភាពខ្ពស់ ចំពោះមូលបត្ររដ្ឋដែលចារឹកជារូបិយវត្ថុជាតិ ឬជារូបិយបណ្ណ នៅក្នុងការគណនាអនុបាតក្របខ័ណ្ឌសន្ទនីយភាព។

សារាចរណែនាំនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ទេសាភិបាល

ជា_ចាន់តូ

**កន្លែងទទួល៖**

- អគ្គលេខាធិការដ្ឋាន
- អគ្គនាយកដ្ឋានត្រួតពិនិត្យ
- អគ្គនាយកដ្ឋានបច្ចេកទេស
- អគ្គបេឡា
- អគ្គាធិការដ្ឋាន
- គ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧